ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ..........ស.ភ.រ

# សេចក្តីជូនដំណឹង

អនុលោមតាមសេចក្តីសម្រេចលេខ៣៩៥១ មស.សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការជំនាន់ទី៨ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់ និស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងឡើងទៅ និងនិស្សិតដែលទើបបញ្ចប់ការសិក្សាឆ្នាំទី២ដោយជោគជ័យក្នុងឆ្នាំ២០១៨នេះ និងមន្ត្រីរាជការទាំងអស់ ឱ្យបានជ្រាបថា សាលា នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការ ជំនាន់ទី៨ ចំនួន១២០នាក់ បេក្ខជនត្រូវជ្រើសរើសភាសាជាមុនក្នុងការដាក់ពាក្យ សម្រាប់ការបណ្តុះបណ្តាលឆ្នាំ២០១៩។

- លក្ខខណ្ឌនៃការជ្រើសរើស សូមមើលក្នុងសេចក្តីសម្រេចលេខ៣៩៥១ មស.សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ
- កាលបរិច្ឆេទបំពេញពាក្យតាម Online ចាប់ផ្តើមពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ តទៅ តាមគេហទំព័រ sms.era.gov.kh ឬអាចមកបំពេញពាក្យសុំប្រឡងតាម Online នៅសាលាភូមិន្ទរដ្ឋបាល
- កាលបរិច្ឆេទ នៃការទទួលពាក្យ នឹងចាប់ផ្តើមពីថ្ងៃ២៦ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង ១៧ម៉៣០នាទី ជាពេលផុតកំណត់
- សូមភ្ជាប់មកជាមួយនូវរូបថតថ្មី ៤x៦ ចំនួន៤សន្លឹក (ផ្ទៃខាងក្រោយពណ៌ស) និងឯកសារច្បាប់ដើមរួមមាន សំបុត្រកំណើត សញ្ញាបត្រ(ចាប់ពីបរិញ្ញាបត្ររងឡើងទៅ),ប្រកាសតាំងស៊ប់ និងលិខិតបញ្ជាក់បច្ចុប្បន្នភាព(សម្រាប់មន្ត្រីរាជការ) រួមទាំងច្បាប់ថតចម្លងដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- ការប្រឡងប្រជែងនឹងប្រព្រឹត្តនៅក្នុងសប្តាហ៍ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៨ រីឯកាលបរិច្ឆេទជាក់ស្តែង នឹងត្រូវប្រកាសបិទផ្សាយជូននៅពេលក្រោយ និងនៅលើគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល។

<u>បញ្ជាក់៖</u>

- ការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ ៤៥.០០០៛(សែសិបប្រាំពាន់រៀលគត់)។

ចំពោះព័ត៌មានលម្អិតផ្សេងៗទៀត មាននៅលើគេហទំព័រសាលា www.era.gov.kh ឬសូមទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាល ឬតាមលេខទូរស័ព្ទរៀងរាល់ម៉ោងធ្វើការដូចខាងក្រោម៖

០១១ ៩៩ ៥៨ ៥៤    ០១៥ ៩៦ ៩៧ ២១    ០៩៧ ៩៧ ៥១ ៥៧២

អាស្រ័យហេតុនេះ សូមបេក្ខជន ជានិស្សិត និងមន្ត្រីរាជការទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ ........... ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៨

**សាលាភូមិន្ទរដ្ឋបាល**

ចម្លងជូន៖

- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាឡឹកជូឡុង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658
អ៊ីមែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៥៤១ មស.សស

# សេចក្តីសម្រេច
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៨

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ-បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្របក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- យោងសំណើរបស់នាយកសាលាភូមិន្ទរដ្ឋបាល ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨



ផ្លូវវិថីព្រះមហាក្សត្រ ... ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

# សម្រេច

**ប្រការ ១ ._** ត្រូវបានអនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលមន្ត្រីក្រមការ លើកទី៨ ចំនួន ១២០នាក់ នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការតាមក្រសួង ស្ថាប័ន និងនិស្សិត។ បេក្ខជនដែលប្រឡងជាប់នឹងត្រូវរៀនរយៈពេល ១ឆ្នាំ។ កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៨។

**ប្រការ ២ ._** លក្ខខណ្ឌជ្រើសរើស ៖

- បេក្ខជនទាំងពីរភេទជានិស្សិតត្រូវមានអាយុយ៉ាងច្រើនបំផុត២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតឧត្តមភូមិ បូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- បេក្ខជនទាំងពីរភេទជាមន្ត្រីរាជការត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅពេលប្រឡងជាប់ជាស្ថាពរ
- ត្រូវមានលិខិតពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។
- បញ្ជីបេក្ខជនដែលអនុញ្ញាតឱ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ក្រសួងមុខងារសាធារណៈ។

**ប្រការ ៣ ._** វិញ្ញាសាប្រឡងប្រជែងរួមមាន ៖ វិញ្ញាសាសរសេរលើកទី១ និងវិញ្ញាសាសរសេរលើកទី២

ក- វិញ្ញាសាសរសេរលើកទី១ ៖

សំណួរពហុចម្លើយ និងអធិប្បាយខ្លី "រយៈពេល ២ម៉ោង៣០នាទី "

**មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២។**

ខ- វិញ្ញាសាសរសេរលើកទី២ ៖

១- អធិប្បាយ ជ្រើសរើស ពាក់ព័ន្ធនឹងចំណេះដឹងទូទៅ ( ច្បាប់ រដ្ឋបាល, សេដ្ឋកិច្ច, វប្បធម៌ទូទៅ) និងសំណួរខ្លី ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ, ភូមិសាស្ត្រ, សីលធម៌ ពលរដ្ឋវិទ្យា, អរិយធម៌វប្បធម៌ "រយៈពេល ៣ម៉ោង " មេគុណ ១

២- ភាសាអង់គ្លេស ឬភាសាបារាំង "រយៈពេល ១ម៉ោង ៣០នាទី" មេគុណ ១

**ប្រការ ៤ ._** វិញ្ញាសាសរសេរត្រូវរក្សាអនាមិកភាព។ វិញ្ញាសានីមួយៗត្រូវកែជាពីរលើក និងត្រូវផ្តល់ពិន្ទុលើ ១០០។

**ប្រការ ៥ ._** ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលា។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ ៦ .-** ការទទួលស្គាល់ជាសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល ត្រូវធ្វើដោយសេចក្ដីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ សិស្សត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ ៧ .-** ក្រុមប្រឹក្សាសាលា នាយកសាលាភូមិន្ទរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ